# និន្នាការសេដ្ឋកិច្ចសង្គម

# Socio-Economic Trends

**ប្រចាំខែកញ្ញា ឆ្នាំ២០១៦ / September 2016**

## មាតិកា


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប / Executive summary** | **២** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends** | **៥** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index | ៥ |
| ១.២. វិស័យហិរញ្ញវត្ថុ / Finance | ៦ |
| ១.៣. វិស័យពាណិជ្ជកម្ម / Trade | ៨ |
| ១.៤. ការអនុវត្តថវិកា / Budget execution | ១០ |
| ១.៥. វិស័យវិនិយោគឯកជន / Private investment | ១១ |
| ១.៦. វិស័យទេសចរណ៍ / Tourism | ១១ |
| ១.៧. វិស័យសំណង់ / Construction | ១២ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ / International commodity prices** | **១៣** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | ១៣ |
| ២.២. ថ្លៃអង្ករ (Rice price: 5%, 25%, 100% broken) | ១៣ |
| ២.៣. ថ្លៃកៅស៊ូ (Rubber price: TSR20, SGP/MYS) | ១៣ |
| **៣. ឧបសម្ព័ន្ធ** | **១៤** |

## ខ្លឹមសារសង្ខេប

**១.** សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញក្នុងខែកញ្ញា ឆ្នាំ២០១៦ បានកើនឡើង ០,៣% ធៀបនឹងខែមុន និងបានកើនឡើង ៣,០% ធៀបនឹង១២ខែមុន។ ធៀបនឹងខែមុន សន្ទស្សន៍ថ្លៃនៃក្រុមទំនិញដែលបានកើនឡើងគួរកត់សម្គាល់រួមមាន អាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង សម្លៀកបំពាក់ និងស្បែកជើង និងគ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំ, រីឯសន្ទស្សន៍ថ្លៃនៃក្រុមទំនិញដទៃទៀតហាក់នៅនឹងឬមានការថយចុះតិចតួច។ តាមការធ្វើចំណោលគិតដល់ត្រឹមខែធ្នូ ឆ្នាំ២០១៦ អតិផរណាប្រចាំឆ្នាំ(year on year)អាចមានអត្រា ៣,៥% ឬអតិផរណាមធ្យមប្រចាំឆ្នាំ(year average) ២,៩%។

**២.** គិតត្រឹមខែសីហា ឆ្នាំ២០១៦ រូបិយវត្ថុទូទៅM2មាន ៥៦.៧៩៨ប៊ីលានរៀល កើនឡើង ២,១% ធៀបនឹងខែមុន និងបានកើនឡើង ២១,៦% ធៀបនឹង១២ខែមុន, ក្នុងនោះប្រាក់រៀល(រូបិយវត្ថុM1 និងប្រាក់បញ្ញើជារៀល) មានសមាមាត្រត្រឹមប្រមាណ ១៦% នៃរូបិយវត្ថុទូទៅM2 ទោះមានកំណើនបន្តិចចាប់ពីខែឧសភាមកក្តី។ គោលនយោបាយនិងប្រតិបត្តិការមួយចំនួនដើម្បីបង្កើនការប្រើប្រាស់ប្រាក់រៀលមានដូចជា÷ ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់, ការកំណត់ប្រាក់បម្រុងកាតព្វកិច្ចជារៀលក្នុងអត្រា(៨%)ទាបជាងរូបិយប័ណ្ណបរទេស(១២,៥%), ការដាក់ចេញឧបករណ៍ហិរញ្ញវត្ថុNCDជារៀល, អនុវត្តប្រតិបត្តិការផ្តល់សន្ទនីយភាពដោយមានការធានា(Lquidity-Providing Collateralised Operation), និងដាក់ឲ្យដំណើរការប្រព័ន្ធទូទាត់ប្រាក់រៀល"Fast System"ជាដើម, ប៉ុន្តែទោះយ៉ាងនេះក្តី ដុល្លាររូបនីយកម្មនៅកម្ពុជានៅមានកម្រិតខ្ពស់នៅឡើយ ស្របពេលដែលមានលំហូរចូលខ្ពស់នៃមូលទុនពីបរទេស។

កំណើនឥណទានបានថយល្បឿនជាបន្តបន្ទាប់ គិតត្រឹមខែសីហា ឆ្នាំ២០១៦ ឥណទានដែលផ្តល់ដោយធនាគារពាណិជ្ជមាន ៥៥.៦១៣ប៊ីលានរៀល បានកើនឡើង ០,៥% ធៀបនឹងខែមុនដែលជាកំណើនទាប, បើធៀបនឹង១២ខែមុនបានកើនឡើង ២៤,២% ដែលជាកំណើនដ៏ទាបផងដែរបើធៀបនឹងបណ្តាឆ្នាំមុនៗ។

ក្នុងខែសីហា ឆ្នាំ២០១៦ អត្រាការប្រាក់នៃធនាគារពាណិជ្ជបានថយចុះបន្តិចទាំងប្រាក់បញ្ញើនិងប្រាក់កម្ចីធៀបនឹងខែកន្លងទៅ, រីឯអត្រាការប្រាក់នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពុំមានការប្រែប្រួលទេ។ តាមការសង្កេត អត្រាការប្រាក់នៅកម្ពុជាមានកម្រិតខ្ពស់ជាងប្រទេសជិតខាងក្នុងតំបន់ ដែលនេះបង្ហាញផងដែរអំពីសក្តានុពលកំណើនសេដ្ឋកិច្ចកម្ពុជា។

**៣.** ការនាំចូល÷ ក្នុងខែកញ្ញានេះ ការនាំចូលបានបន្តថយចុះមកត្រឹម ៩៦៧លានដុល្លារ ក្នុងនោះមានការថយចុះខ្លាំងលើការនាំចូលវាយនភ័ណ្ឌ និងទំនិញផ្សេងៗ រីឯបរិក្ខារសំណង់បានកើនឡើងគួរកត់សម្គាល់។ ក្នុងរយៈពេល៩ខែ ឆ្នាំ២០១៦នេះ ការនាំចូលជាទឹកប្រាក់សរុប ៩.១៥២លានដុល្លារ បានកើនឡើង ៥,៣% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះចំណែកនៃការនាំចូលទំនិញវាយនភ័ណ្ឌមាន ២៩,២% បរិក្ខារសំណង់ ៤,៦% គ្រឿងយន្ត ៨,៧% ប្រេងឥន្ធនៈ ១០,៤% និងទំនិញផ្សេងៗទៀត ៤៧,១%។

ការនាំចេញ÷ ក្នុងខែកញ្ញានេះ ការនាំចេញបានថយចុះបន្តិចមកត្រឹម ៩០២លានដុល្លារ ក្នុងនោះមានការថយចុះខ្លាំងលើប្រភេទទំនិញវាយនភណ្ឌ និងប្រភេទទំនិញផ្សេងៗ, ប៉ុន្តែផលិតផលអង្ករនាំចេញបានកើនឡើងខ្ពស់ និងការនាំចេញកៅស៊ូក៏បានកើនឡើងផងដែរធៀបនឹងខែកន្លងទៅ។ រយៈពេល៩ខែ ឆ្នាំ២០១៦នេះ ការនាំចេញសរុបមាន ៧.៧៣០លានដុល្លារ

បានកើនឡើង ១១,៣%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ក្នុងនោះចំណែកនៃការនាំចេញផលិតផលវាយនភ័ណ្ឌនិងស្បែកជើង មាន ៧៣,៦% អង្ករ ២,៦% កៅស៊ូ ១,៤% និងផលិតផលផ្សេងៗទៀត ២២,៤%។

**៤.** ការអនុវត្តចំណូល÷ ក្នុងខែកញ្ញា ឆ្នាំ២០១៦ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណូលក្នុងប្រទេសបាន ១.១២៧ប៊ីលានរៀល បានកើនឡើងបន្តិចធៀបនឹងខែកន្លងទៅ ប៉ុន្តែមានកម្រិតទាបជាងបណ្តាខែមុនៗ។ ក្នុងរយៈពេល៩ខែឆ្នាំ២០១៦នេះ ចំណូលក្នុងប្រទេសសរុបអនុវត្តបាន ១០.៧៩៧ប៊ីលានរៀល បានកើនឡើង ១៩,៨%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន (ច្រើនជាងច្បាប់ថវិកាឆ្នាំ២០១៦ប្រមាណ ៤,៨%), ក្នុងនោះចំណែកនៃចំណូលសារពើពន្ធមាន ៨៧,៧% ចំណូលមិនមែនសារពើពន្ធមាន ១១,៦% និងចំណូលមូលធនមាន ០,៦%។

ការអនុវត្តចំណាយ÷ ក្នុងខែកញ្ញា ឆ្នាំ២០១៦ រដ្ឋបាលថ្នាក់ជាតិបានអនុវត្តចំណាយថវិកា ១.២០៣ប៊ីលានរៀល បានកើនឡើង ២០,៨%ធៀបនឹងខែមុន ប៉ុន្តែបានថយចុះ ១២,៦%ធៀបនឹងខែកញ្ញាឆ្នាំមុន។ ក្នុងរយៈពេល៩ខែឆ្នាំ២០១៦ ចំណាយអនុវត្តសរុប ៩.០៩១ប៊ីលានរៀល បានកើនឡើង ៤,៩%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន (ប៉ុន្តែទាបជាងច្បាប់ថវិកាឆ្នាំ២០១៦ប្រមាណ ២១,៤%), ក្នុងនោះចំណែកនៃចំណាយបៀវត្សមាន ៤២,៦% ចំណាយមិនមែនបៀវត្ស ២៩,៨% និងចំណាយមូលធន ២៧,៦%។

ជារួមក្នុងរយៈពេល៩ខែឆ្នាំ២០១៦នេះ ការអនុវត្តចំណូលបានកើនឡើងក្នុងល្បឿនលឿនជាងការអនុវត្តចំណាយធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ជាលទ្ធផលរយៈពេល៩ខែនេះ តុល្យភាពចរន្តសរុបមានអតិរេក ៣.៩៩៨ប៊ីលានរៀល និងតុល្យភាពថវិកាទូទៅមានអតិរេក ១.៥៥៦ប៊ីលានរៀល, ដែលនេះបង្ហាញពីកិច្ចខិតខំប្រឹងប្រែងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការកៀងគរចំណូល និងកែទម្រង់ហិរញ្ញវត្ថុសាធារណៈឲ្យកាន់តែមានប្រសិទ្ធភាពក្នុងការអនុវត្តថវិកា។

**៥.** ក្នុងខែកញ្ញា ឆ្នាំ២០១៦ គម្រោងវិនិយោគអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានទុនវិនិយោគ ១០៣លានដុល្លារ បានកើនឡើង ៣ដងធៀបនឹងខែមុន ក្នុងនោះមានគម្រោងវិនិយោគធំៗមួយចំនួនលើផ្នែកកសិ-ឧស្សាហកម្ម (គម្រោងវិនិយោគកសិដ្ឋាននិងកែច្នៃផលិតផលកសិកម្ម ០១គម្រោង ជាមួយវិនិយោគទុន ៣៥លានដុល្លារ) និងផ្នែកឧស្សាហកម្មរ៉ែ (គម្រោងឧស្សាហកម្មរ៉ែមាស ០១គម្រោង ជាមួយទុនវិនិយោគ ២០លានដុល្លារ)។

រយៈពេល៩ខែ ឆ្នាំ២០១៦នេះ ចំនួនគម្រោងវិនិយោគមាន ៩៣គម្រោង(ស្មើនឹងរយៈពេលដូចគ្នាឆ្នាំមុន), គិតជាទុនវិនិយោគសរុប ២.៧៤២លានដុល្លារ ស្រូបកម្លាំងពលកម្មសរុបចំនួន ១០០ពាន់នាក់។ តាមការសង្កេត វិនិយោគបានកើនឡើងខ្លាំងទៅលើវិស័យឧស្សាហកម្ម និងទេសចរណ៍, ធៀបនឹងរយៈពេល៩ខែឆ្នាំមុន វិនិយោគវិស័យឧស្សាហកម្ម បានកើនឡើង ២ដង ក្នុងនោះវិនិយោគទុនលើរោងចក្រស៊ីម៉ងត៍មានចំណែក ៥៥%, និងវិនិយោគវិស័យទេសចរណ៍បានកើនឡើង ២១ដង ដោយមានគម្រោងវិនិយោគធំៗទៅលើមជ្ឈមណ្ឌលទេសចរណ៍ អភិវឌ្ឍន៍តំបន់ទេសចរណ៍ធម្មជាតិ និងសណ្ឋាគារផ្កាយប្រាំ។

**៦.** ក្នុងខែសីហា ឆ្នាំ២០១៦ ចំនួនភ្ញៀវអន្តរជាតិបានកើនឡើង ២,៦%ធៀបនឹងខែមុន។ តាមការសង្កេត ចំនួនភ្ញៀវអន្តរជាតិអាចនឹងថយចុះតិចតួចក្នុងខែកញ្ញា និងចាប់កើនឡើងជាបន្តបន្ទាប់ពីខែតុលាដល់ដើមឆ្នាំបន្ទាប់។ រយៈពេល៨ខែឆ្នាំ២០១៦នេះ ចំនួនភ្ញៀវអន្តរជាតិកើនឡើងបាន ៤,៣% គឺមានចំនួនសរុប ៣.១៦៣ពាន់នាក់ ក្នុងនោះភ្ញៀវមកពីតំបន់អាស៊ីច្រើនជាងគេ ជាពិសេសតំបន់អាស៊ាន។

**៧.** វិស័យសំណង់បានបន្តកើនឡើងខ្លាំង រយៈពេល៩ខែ ឆ្នាំ២០១៦នេះ សំណើសាងសង់សរុបមាន ២.០០៩គម្រោង (កើន៥០៤គម្រោងធៀបនឹង៩ខែឆ្នាំមុន), គិតជាផ្ទៃក្រឡាសំណង់សរុប ១២.២៦៩ពាន់ម៉ែត្រការ៉េ បានកើនឡើង ១៦៨%ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន, ក្នុងនោះមានការហក់ឡើងគួរកត់សម្គាល់ចំពោះសំណង់ប្រភេទអាគារពាណិជ្ជកម្ម (កើន ៨ដង) សំណង់ប្រភទលំនៅដ្ឋាន (កើន ៦៥%) និងសំណង់ប្រភេទឧស្សាហកម្ម (កើន ១១០%), គិតជាទឹកប្រាក់សរុប ៧.៥៦០លានដុល្លារ បានកើនឡើង ៣ដងធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

៨. *ថ្លៃប្រេងឆៅ* ជារួមថ្លៃប្រេងនៅលើទីផ្សារអន្តរជាតិមាននិន្នការកើនឡើងនៅចុងខែកញ្ញានេះ។ នៅខែកញ្ញា ឆ្នាំ២០១៦ សម្រាប់ប្រេងឆៅក្នុងកិច្ចសន្យាលក់១ខែខាងមុខ ប្រេងBrentថ្លៃ ៤៦,១៩ដុល្លារ/ ធុង បានកើន ០.១% ធៀបនឹងខែមុន ប្រេងDubaiថ្លៃ ៤៣,៧៤ដុល្លារ/ ធុង បានកើន ០.០២% និងប្រេងWITថ្លៃ ៤៥,២ដុល្លារ/ ធុង បានកើន ១,០%។ កំណើនថ្លៃប្រេងក្នុងខែកញ្ញានេះ គឺដោយសារបណ្តាប្រទេសOPECបានសម្រេចកិច្ចព្រមព្រៀងកាត់បន្ថយនិន្នផលប្រេង ដែលនឹងចាប់អនុវត្តចាប់ពីខែវិច្ឆិកាតទៅ។

*ថ្លៃអង្ករ* នៅខែកញ្ញា ឆ្នាំ២០១៦ (១)អង្ករកម្ពុជា អង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៤២៥ដុល្លារ/តោន បានថយចុះ ២,៣% ធៀបនឹងខែមុន និងបានកើនឡើង ១,២% ធៀបនឹង១២ខែមុន, ដែលការថយចុះថ្លៃនេះ គឺដោយមានការប្រកួតប្រជែងពីប្រទេសជិតខាង។ (២)អង្ករថៃ នៅទីក្រុងបាងកកអង្ករនាំចេញ(ខ្ទេច៥%)ថ្លៃ ៣៨៤ដុល្លារ/តោន បានថយចុះ ៧,៥% ធៀបនឹងខែមុន និងបានកើនឡើង ៧,៦% ធៀបនឹង១២ខែមុន។ (៣)អង្ករវៀតណាម អង្ករនាំចេញ (ខ្ទេច៥%)ថ្លៃ ៣៤៣ដុល្លារ/តោន គឺបានថយចុះ ១,៤% ធៀបនឹងខែមុន និងបានកើនឡើង ៥% ធៀបនឹង១២ខែមុន។ ការបន្តធ្លាក់ចុះនៃថ្លៃអង្ករនេះ គឺដោយសារមានការប្រកួតប្រជែងការនាំចេញអង្ករនៅក្នុងតំបន់ និងមានកំណើនការផ្គត់ផ្គង់បន្ទាប់ពីរដូវប្រមូលផល។

*ថ្លៃកៅស៊ូ* នៅខែកញ្ញា ឆ្នាំ២០១៦ កៅស៊ូស្តង់ដារTSR20ថ្លៃ ១.៣៥៨ដុល្លារ/តោន បានកើនឡើង ៤,៧% ធៀបនឹងខែមុន និងកើនឡើង ៩,៦% ធៀបនឹង១២ខែមុន, កៅស៊ូSGP/MYSថ្លៃ ១.៥៧៣ដុល្លារ/តោន បានកើនឡើង ១,៣% ធៀបនឹងខែមុន និងកើនឡើង ១៦,៨% ធៀបនឹង១២ខែមុន។ កំណើនថ្លៃនេះ គឺដោយសារប្រទេសឥណ្ឌូនេស៊ី និងថៃបានរងឥទ្ធិពលខ្យល់ព្យុះដែលធ្វើឲ្យប៉ះពាល់ដល់ការផ្គត់ផ្គង់, ថ្លៃវត្ថុធាតុដើមកៅស៊ូធម្មជាតិនៅថៃក៏មានការកើនឡើង, រីឯតម្រូវការនៃការផលិតកម្មសំបកកង់រថយន្តដើម្បីផ្គត់ផ្គង់ទីផ្សារក៏មានការកើនឡើងផងដែរ។

*(ចំពោះសេចក្តីលម្អិតនៃរបាយការណ៍ សូមទាក់ទងផ្ទាល់នាយកដ្ឋានស្ថិតិ នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)*

# ៣. ឧបសម្ព័ន្ធ

## សូចនាករនាំមុខ (Leading Indicators)



Source: Min. LMUC



Source: Ministry of Tourism



Source: Customs and Excise Dept.



Source: Customs and Excise Dept.



Source: MEF & Int.



Source: MEF & Int.

# អតិផរណា និងទុនបម្រុងបរទេស (Inflation and Foreign Reserves)




Source: NBC




Source: NIS




Source: NIS




Source: NIS




Source: NIS




Source: NBC

# អត្រាប្តូរប្រាក់ (Exchange Rate)

**Exchang Rate Mal-Ringgit/$ and Phi-Peso/$**




Source: IMF

**CPI and Exchange rate R/$**




Source: IMF

**Exchange rate EU Euro/US$ and Pound/US$**




Source: IMF

**Exchange rate R/100Đ and R/B**




Source: IMF

**Exchange rate Aus-$ and HK-$**




Source: IMF

**Exchange rate Sing-$ and Yen-$**




Source: IMF

# វិស័យរូបិយវត្ថុ និងធនាគារ (Money and Banking)

**Liquidity in Bn-R and in % to GDP**




Source: NBC

**NFA and NDA (Bn-R)**




Source: NBC

**Credit to private sector, CPS (Stock) and growth**




Source: NBC

**Credit to Private Sectors by Sector (Bn-R)**




Source: NBC

**Currency outside bank, COB and foreign deposits, FD**




Source: NBC

**MFIs and NGOs Loans Outstanding**




Source: NBC

# ការអនុវត្តថវិការ (Budget)


















# វិនិយោគឯកជន និងការបង្កើតការងារ (Investment and Employment)

**CDC Approval, Fixed Assets and Growth (Mn. $)**




Source: CDC

**CDC Approvals- Fixed Assets by Sectors (Mn. $)**




Source: CDC

**Number of Jobs ('000 person)**




Source: CDC

**Public Investment by Source of Finance (Bn.R)**




Source: MEF

**Net Loans Disbursement (Bn.R)**




Source: MEF

**CDC Approvals, Fixed assets by Sources (Mn. $)**




Source: CDC

# វិស័យពាណិជ្ជកម្ម (Trades)




Source: Customs and Excise Department




Source: Customs and Excise Department




Source: National Bank of Cambodia, NBC, and Customs Dept.




Souce: Customs and Excise Department, MEF




Souce: Customs and Excise Department, MEF




Souce: Customs and Excise Department, MEF

*********

**រៀបចំដោយ**

**អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ព័ត៌មានផ្សេងៗ សូមទាក់ទង*

*ទូរស័ព្ទលេខ÷ ០២៣ ៤២៧ ៩១៣, ០១២ ៧៨៧ ៤៨៤, ០១៦ ៨៦៨ ៨១៧, ០៧៧ ៧០៣ ៤៣៦*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ ព្រឹក និង ២:០០ ដល់ ៥:០០ រសៀល*